# សង្ឃឹម...



http://www.freepik.com/free-photo/

សង្ឃឹមមានថ្ងៃថ្ងៃបានស្តាប់
យល់ន័យសារស័ព្ទប្រាប់វរមិត្ត
តាមភ្លេងខ្ញុំតែងថ្លែងការពិត
តែស្នេហ៍ក្នុងចិត្តឥតហ៊ានស្តី។
រឿងចែងវោហារចារនិពន្ធ
មិនខ្វះទេទុនមន្តសម្តី
តែដល់រឿងពិតចិត្តមេត្រី
យូរឆ្នាំមកហើយខំអើយខំ
តាំងពីមាសមេទំនេរប្រាណ
ចិត្តស្នេហ៍នៅនិត្យឥតរសាយ
លេបស្ងាក់ខ្ទាក់ស្ទែងចំបែងជាប់
សង្ឃឹមមានថ្ងៃថ្ងៃបានស្តាប់
តើម្ចាស់ចម្រៀងជាអ្នកណា?

ម្តេចបែរចង្រៃស្តីមិនបាន?
ប្រមូលសន្សំក្តីក្លាហាន
រហូតកល្យាណមានគូគាប់។
ចម្រៀងបរិយាយកាយអក័ព្វ
បានភ្លេងគ្រាន់ទ្រាប់ផ្តាប់ចិន្តា។
ហើយចុចទូរស័ព្ទមកសួរថា
ខ្ញុំនឹងឆ្លើយថាគឺជាអ្នក!

ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុក្រសិរី